ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

**អគ្គលេខាធិការដ្ឋាន គជ.ប.ជ.**
លេខាធិការដ្ឋានរដ្ឋបាល សរុប
ការិយាល័យសរុប ផែនការ

# សូមគោរពជូន

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**តាមរយៈ៖** -លោកឧត្តមសេនីយ៍ទោ ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប
-លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ៖** របាយការណ៍ស្តីពី កិច្ចប្រជុំត្រៀមរៀបចំទិវាជាតអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី៨ ឆ្នាំ២០២៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** មេត្តាជ្រាបថា៖ នៅរសៀលថ្ងៃអង្គារ ៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០២៤ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំត្រៀមរៀបចំទិវាអន្តរសាសនា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លើកទី ៨ ឆ្នាំ ២០២៤ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។ គោលបំណងនៃកិច្ចប្រជុំ គឺរៀបចំទិវាជាតិអន្តរសាសនា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទាសភាពសម័យទំនើប ដែលនឹងប្រារព្ធធ្វើ នៅថ្ងៃទី ២០ ខែសីហា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ។

**សមាសភាពយាងនិមន្ត និងអញ្ជើញចូលរួម៖**

-សម្តេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ
-ព្រះសុមេធវង្សបណ្ឌិត **សុខ ប៊ុនធឿន** តំណាងព្រះសង្ឃគណៈមហានិកាយ
-ព្រះចរិយានុវ័ត្តញាណ **សោម វិជ្ជា** តំណាងព្រះសង្ឃគណៈមហានិកាយ
-ព្រះគ្រូរាជស្ថិតធម្ម **មួង សុខុម** តំណាងព្រះសង្ឃគណៈធម្មយុត្តិកនិកាយ
-ព្រះគ្រូធម្មសាលានុរក្ស **អេង វណ្ណៈ** តំណាងព្រះសង្ឃគណៈធម្មយុត្តិកនិកាយ
-ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងធម្មការ និងសាសនា
-តំណាងក្រសួងកិច្ចការនារី
-ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
-លោកស្រី តំណាងសមាគមសហគ្រិនស្ត្រី
-លោកជំទាវ លោកស្រី តំណាងសមាគមសិល្បៈ
-ប្រធានលេខាធិការដ្ឋាន ទីប្រឹក្សា នាយ នាយរងការិយាល័យ និងមន្ត្រីបច្ចេកទេស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ **សរុបចំនួន ៤៤អង្គ/នាក់ ស្រី ១៨រូប**។

តាមរយៈកិច្ចប្រជុំពិភាក្សាគ្នា ក៏មានការចូលរួមផ្ដល់នូវសង្ឃដិកាអប់រំ និងមានការចែករំលែកបទពិសោធន៍ ផ្ដល់នូវមតិយោបល់ជាច្រើនពីសមាជិក សមាជិកា ក្នុងកិច្ចប្រជុំ។ ទាក់ទងនឹងវិស័យពុទ្ធសាសនា ក្នុងការចូលរួមផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្ដេចព្រះមហាអរិយវង្សបណ្ឌិត **យ៉ន សេងយៀត** ព្រះសាកលវិទ្យាធិការ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មានព្រះបន្ទូលថា វិស័យពុទ្ធសាសនា បានចូលរួមជាច្រើន ក្នុងការផ្សព្វផ្សាយអប់រំផ្លូវចិត្តពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រាន់តែមិនបានផ្សព្វផ្សាយឱ្យបានទូលំទូលាយតែប៉ុណ្ណោះ។

ឆ្លងតាមការពិភាក្សា កិច្ចប្រជុំបានទទួលនូវសារអប់រំ សំខាន់ៗមួយចំនួនសម្រាប់ប្រើជាបដា ពាក្យស្លោក នៅក្នុងពេលប្រារព្ធពិធីនាពេលខាងមុខ ក្នុងនោះមានដូចជា៖

**-តំណាងព្រះសង្ឃ** (១-ការជួញដូរមនុស្ស គឺជាអំពើបាប, ២-រួមគ្នាប្រយុទ្ធប្រឆាំង/បង្ការទប់ស្កាត់អំពើជួញដូរមនុស្ស)

**-តំណាងក្រសួងធម្មការ និងសាសនា** (១-ការអប់រំសីលធម៌, ២-ការអប់រំល្អ ជាតម្លៃរបស់មនុស្ស)

**-តំណាងក្រសួងព័ត៌មាន (វិទ្យុ ទូរទស្សន៍)** (១-សុខដុមនីយកម្មសាសនា រួមគ្នាប្រឆាំងការអូសទាញ និងប្រឆាំងអំពើជួញដូរក្នុងសម័យឌីជីថល, ២-ការលើកកម្ពស់ការចូលរួមរបស់យុវជនប្រឆាំងការជួញដូរមនុស្សក្នុងសម័យឌីជីថល, ៣-លើកកម្ពស់សុចរិតភាព វិទ្យាសាស្ត្រវិទ្យាក្នុងសម័យ ឌីជីថល)

**-តំណាងសមាគមសហគ្រិនស្ត្រី** (ពណ៌សង្គមមនុស្សជាតិ)

**-តំណាងសមាគមសិល្បៈ** (ខុសមួយជំហាន ខុសមួយជីវិត)

**-តំណាងគ.ជ.ប.ជ** (១-លើកកម្ពស់សីលធម៌សង្គម ជាវិធានការអប់រំ ដើម្បីបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស, ២-វិទ្យាសាស្ត្រខ្វះសីលធម៌ បំផ្លាញមនុស្សជាតិ)។

ជាចុងបញ្ចប់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានទទួលយកបណ្ដាសារអប់រំជាធាតុចូល ដែលបានផ្ដល់ដោយ សមាជិក សមាជិកា កិច្ចប្រជុំទាំងអស់ខាងលើ ហើយនឹងរៀបចំធ្វើជាពាក្យស្លោក ឬបដាអប់រំ នៅពេលកម្មវិធី ប៉ុន្តែនៅឆ្នាំនេះ លោកជំទាវ ចង់បានសារ ឬប្រធានបទគន្លឹះមួយសម្រាប់ជា តែម (Stamp) ប្រចាំឆ្នាំ២០២៤ នេះតែម្ដង។ កិច្ចប្រជុំដើម្បីត្រៀមរៀបចំទិវាជាតិអន្តរសាសនា លើកទី៨ ឆ្នាំ ២០២៤ នឹងបន្តការជជែកពិភាក្សាគ្នាជាបន្តបន្ទាប់ទៀត ដើម្បីធានាថា ការប្រារព្ធពិធី នៅថ្ងៃទី២០ ខែសីហា ឆ្នាំ ២០២៤ខាងមុខ ប្រកបដោយភាពរលូន និងទទួលបានជោគជ័យ។

អាស្រ័យហេតុនេះ សូម ***លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ*** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ៕

*ថ្ងៃ...ពុធ...៥កើត...ខែ...អាសាឍ...ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ,ថ្ងៃទី...១០....ខែ.កក្កដា.ឆ្នាំ២០២៤*

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក.អ៊ុច ចាន់ឆា

*បានពិនិត្យ និងគោរពជូន*
*លោកជំទាវ អគ្គលេខាធិការ មេត្តាជ្រាបជារបាយការណ៍។*
*ថ្ងៃ.ពុធ...៥..កើត..ខែ.អាសាឍ.ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ,ថ្ងៃទី..១០...ខែ.កក្កដា..ឆ្នាំ២០២៤*

**ប្រធានលេខាធិការដ្ឋានរដ្ឋបាលសរុប**

ឧត្តមសេនីយ៍ទោ. ថោង_ឫទ្ធី

បានឃើញ
17/07/24

ជូ_ប៊ុនអេង

*បានពិនិត្យ និងគោរពជូន*
*លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។*
*ថ្ងៃ.ព្រហ.៦.កើត.ខែ.អាសាឍឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ,ថ្ងៃទី.១១..ខែ.កក្កដា.ឆ្នាំ២០២៤*

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់